សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៩០
ចុះថ្ងៃទី០៦-០២-២០១២
សាលដីកា
លេខ: ៦៣ ក្រ៥.ប
ចុះថ្ងៃទី១៣-៩-២០១៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## នាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៣-៨-២០១៣ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៩០ ចុះថ្ងៃទី០៦-០២-២០១២ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ហៅ រីណា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលចាប់ខ្លួន ស្នាក់នៅផ្ទះ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ ឃុំខ្លួន ថ្ងៃទី១៧-១០-២០១១ ។ (ម₁)

ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ មានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អាវុធ ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៩៦៥E, បន្ទប់ជួលលេខ ៣ ផ្លូវព្រះសីហនុ ភូមិទី១ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨-១០-២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៤០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៅ ៣ ភេទស្រី អាយុ២៥ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះ [redacted] ។

- តាមបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច សេចក្ដីសម្រេចទាំងមូល ។

**<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>**

កាលពីថ្ងៃទី០៨-១០-២០១១ វេលាម៉ោង ២៣.២៥នាទី ឈ្មោះ [redacted] គឹមស្រស់ ហៅ រីណា ភេទប្រុស អាយុ២២ឆ្នាំ (អតីតជាប្អូនថ្លៃ) របស់ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណា ហៅ ៣ បានមកគោះទ្វារបន្ទប់ជនរងគ្រោះដែលកំពុងសម្រាកនៅផ្ទះជួលលេខ ៤៦៤E, បន្ទប់ជួលលេខ៣ ផ្លូវព្រះសីហនុ ភូមិទី១ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនរងគ្រោះក៏បើកទ្វារឲ្យ ជនជាប់ចោទសុំជនរងគ្រោះដេកជាមួយតែជនរងគ្រោះបានបដិសេធ និងអង្វរថា ខ្លួនមានជម្ងឺទើបតែកាត់ពោះវៀនដុះខ្នែង ហើយបានដេញជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ចេញពីបន្ទប់ ជនជាប់ចោទក៏ដកកូនព្រួញពីចង្កេះផ្ទុងគំរាមសង្កត់លើដើមដៃជនរងគ្រោះ រួចផ្ដួលចាប់រំលោភរហូតបានសម្រេច លុះដល់ថ្ងៃទី១៣-១០-២០១១ វេលាម៉ោង ២២.៥៦នាទីយប់ ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ បានមកបន្ទប់ជួលរបស់ជនរងគ្រោះម្ដងទៀត ដោយមានកាំបិតប៉ុងតោ១ និងកាំបិតចុងស្រួច១មកគោះទ្វារបន្ទប់ និងស្រែកគំរាមឲ្យជនរងគ្រោះបើកទ្វារឲ្យ តែជនរងគ្រោះមិនហ៊ានបើកក៏តេទូរស័ព្ទប្ដឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចមកដល់ក៏ចាប់ឃាត់ខ្លួនជនជាប់ចោទទៅ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

១- ផ្ដន្ទាទោសឈ្មោះ [redacted] គឹមស្រស់ ហៅ រីណា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ (ដប់ឆ្នាំ) ពីបទ រំលោភសេពសន្ថវៈ មានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អាវុធ ប្រព្រឹត្តនៅផ្ទះជួលលេខ ៤៦៤E1 បន្ទប់ជួលលេខ៣ ផ្លូវព្រះសីហនុ ភូមិ១១ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៤០, ២៤១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

២- វត្ថុចាប់យកមាន:

ក- ម៉ូតូកែច្នៃពណ៌ខ្មៅចំនួន ០១គ្រឿង (ចាស់ទ្រុឌទ្រោម) និងទូរស័ព្ទដៃម៉ាកណូគៀពណ៌ខ្មៅស៊េរី ៧២.១០ មានស៊ីម (បើកមិនចេញ) ចំនួន ០១គ្រឿង ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ខ- កាំបិតចុងស្រួចដងពណ៌ខ្មៅចំនួន ១ និងកាំបិតប៉ុងតោដងពណ៌ខ្មៅចំនួន ១ ត្រូវរឹបអូស និងបំផ្លាញចោល ។

៣- សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី តែចាត់ជា ចំពោះមុខ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ហៅ រីណា បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្ដីសម្រេចទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី២៩-៨-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី០៩-០១-២០១៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ (វត្តមាន)
- មានមេធាវីការពារលោក [redacted] វិបុល (វត្តមាន)
- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណា (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

- ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ បានឆ្លើយថា ខ្លួនទទួលស្គាល់កំហុសអស់ហើយ តែខ្លួនប្ដឹងឧទ្ធរណ៍មកនេះដោយចង់ឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសដល់ខ្លួនផង ។

## តំណាងមហាអយ្យការសន្និដ្ឋានថា:

ការសម្រេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកដដែល ។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋាន:

- លោក [redacted] វិបុល មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា ដោយមានមនោសញ្ចេតនារវាងជនជាប់ចោទ និងដើមបណ្ដឹង ទើបដើមបណ្ដឹងបានដកពាក្យបណ្ដឹងវិញ ដើម្បីសុំឲ្យកូនក្ដីខ្លួនបានរួចខ្លួន ។ សំណូមពរ សុំឲ្យតុលាការឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់នេះ ។

- ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាឧទ្ធរណ៍យល់ឃើញថា:</u>**

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូលរបស់សាលាដំបូងរាជធានីភ្នំពេញ បណ្ដឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២- តាមអង្គហេតុករណីចាប់រំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] សុវណ្ណា ហៅ ពៅ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ ៨៦៨E₁ បន្ទប់ជួលលេខ ៣ ផ្លូវព្រះសីហនុ ភូមិទី១ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨-១០-២០១១ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជនល្មើសបានជាក់ស្ដែងនៅកន្លែងកើតហេតុ ខណៈពេលដែលជនល្មើសព្យាយាមគាស់ទ្វារចូលទៅរករំលោភសេពសន្ថវៈជាលើកទី២ តែជនរងគ្រោះបានទូរស័ព្ទសុំឲ្យសមត្ថកិច្ចអន្តរាគមន៍ទាន់ពេលវេលា ។

៣- នៅគ្រប់ដំណាក់កាលស៊ើបអង្កេតក៏ដូចជានៅចំពោះមុខសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ទទួលស្គាល់អង្គហេតុថា ពិតជាបានប្រព្រឹត្តអំពើលើជនរងគ្រោះឈ្មោះ [redacted] សុវណ្ណា ហៅ ពៅ ដូចការចោទប្រកាន់របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ប្រាកដមែន តែខ្លួនប្ដឹងឧទ្ធរណ៍មកនេះសុំឲ្យសាលាឧទ្ធរណ៍ពិចារណាលើទណ្ឌកម្មរបស់ខ្លួនដែលសាលាដំបូងរាជធានីភ្នំពេញដាក់មកនេះរយៈពេល ១០ឆ្នាំ ឃើញថា ច្រើនពេកការស្នើសុំនេះសាលាឧទ្ធរណ៍ពុំគប្បីលើកមកពិចារណាទេ ដោយហេតុថា ការប្រព្រឹត្តរបស់ជនជាប់ចោទរូបនេះមានលក្ខណៈសាហាវមិនលើកលែង សូម្បីតែជនរងគ្រោះអង្វរថា ខ្លួននៅមានជម្ងឺ ជនជាប់ចោទបានយកពូថៅគំរាមសម្លាប់ ក្រោយមកទៀតបានយកកាំបិតប៉ុងតោ១ កាំបិតចុងស្រួច១ ទៅគាស់ទំលុះទំលាយទ្វារបន្ទប់ជនរងគ្រោះបំរុងចាប់ជនរងគ្រោះរំលោភម្ដងទៀត តែសកម្មភាពនេះត្រូវអាក់ខានទៅវិញដោយសមត្ថកិច្ចមកទាន់ឃាត់ខ្លួនបានជាក់ស្ដែង ដូចនេះជនជាប់ចោទគប្បីទទួលនូវទណ្ឌកម្មតាមច្បាប់ជាធរមាន ។

៤- រឿងក្ដីនេះសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>ទនិច្ឆ័យសេចក្ត</u>

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៦ ក្រ២ គ ចុះថ្ងៃទី២៧-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបាននការដដែល ។

៣- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤- សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី២៣-៨-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមស្រស់ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៅ ៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៣-៩-២០១៣ ។

- បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

<u>សេចក្ដីនេះ</u> <u>ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា</u> <u>ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក</u> <u>អនុវត្តសាលដីកា</u> <u>ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់</u> <u>គ្រប់តំណែង</u> <u>និងកងកំលាំងប្រដាប់អាវុធជួយ</u> <u>សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច</u> <u>ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់</u> ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី...ខែ...ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]